**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ១៨៣ ព.ណ.អ.ក.ប.ប.ប្រក

# ប្រកាស
## ស្តីពី
## បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យនិងស៊ើបអង្កេត ក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- បានឃើញសេចក្តីសម្រេចលេខ៩៥ សសរ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## សម្រេច

**ប្រការ១ ._**

ប្រកាសនេះ កំណត់អំពីបែបបទនិងនីតិវិធីនៃការត្រួតពិនិត្យនិងស៊ើបអង្កេត ចំពោះបទល្មើសក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់អ្នកប្រើប្រាស់ តាមរយៈការត្រួតពិនិត្យ និងស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។

**ប្រការ២ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការត្រួតពិនិត្យ និងស៊ើបអង្កេត រាល់បទល្មើសក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដែលត្រូវអនុវត្តដោយមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «ក.ប.ប.»។

**ប្រការ៣ ._**

វាក្យស័ព្ទសំខាន់ៗមួយចំនួននៃប្រកាសនេះ មានអត្ថន័យដូចខាងក្រោម៖

១. **បណ្តឹង** សំដៅដល់ការបង្ហាញអំពីការមិនពេញចិត្តចំពោះទំនិញ ឬសេវាណាមួយ ពីអ្នកប្រើប្រាស់ សមាគមអ្នកប្រើប្រាស់ អង្គការ ឬក្រសួង ស្ថាប័នពាក់ព័ន្ធ។

២. **សេចក្តីជូនដំណឹងស្តីពីវិធានការហាមឃាត់ជាបណ្តោះអាសន្ន** សំដៅដល់សេចក្តីជូនដំណឹងដែលមានគោលបំណងផ្អាកជាបណ្តោះអាសន្នការផ្គត់ផ្គង់ ការចែកចាយ ឬការចរាចរណ៍លើទីផ្សារ នូវប្រភេទទំនិញ ឬសេវាទាំងឡាយណាដែលមិនមានភាពអនុលោមតាមបទប្បញ្ញត្តិ និងចេញដោយមន្ត្រីស៊ើបអង្កេត។

៣. **បុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេត** សំដៅដល់បុគ្គលទាំងឡាយណាដែលសង្ស័យថាបានបំពានច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

៤. **មន្ត្រីស៊ើបអង្កេត** សំដៅដល់មន្ត្រីនៃអគ្គនាយកដ្ឋាន ក.ប.ប. ដែលត្រូវបានចាត់ឱ្យស៊ើបអង្កេតបទល្មើសក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

៥. **គ.ជ.ក.ប.** សំដៅដល់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់។

៦. **សិទ្ធិនិងកាតព្វកិច្ច** សំដៅដល់អំណាចក្នុងការអនុវត្តច្បាប់ដែលមានចែងក្នុងមាត្រា៣០ នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

៧. **បុគ្គលពាក់ព័ន្ធ** សំដៅដល់បុគ្គលដែលត្រូវបានសង្ស័យថា មានព័ត៌មាន ឯកសារ ឬវត្ថុដទៃដែលពាក់ព័ន្ធដល់ការស៊ើបអង្កេតបទល្មើសក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

៨. **សំណាកគំរូ** គឺជាផ្នែកមួយឬច្រើននៃទំនិញ ដែលត្រូវបានជ្រើសរើសយកចេញពីឡូតិ៍មួយ ក្នុងគោលបំណងទទួលបាននូវសំណាកគំរូមួយដែលតំណាងឱ្យឡូតិ៍ទំនិញទាំងមូល។

**ប្រការ៤ ._**

មន្ត្រីស៊ើបអង្កេតត្រូវអនុវត្តសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនស្របតាមបែបបទ និងនីតិវិធីដែលមានចែងក្នុងប្រកាសនេះ ដើម្បីត្រួតពិនិត្យ និងស៊ើបអង្កេតបទល្មើសក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

**ប្រការ៥ ._**

មន្ត្រីស៊ើបអង្កេតអាចស្នើសុំកិច្ចសហការពីអាជ្ញាធរមូលដ្ឋាន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ក្នុងការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនតាមការចាំបាច់។

**ប្រការ៦.–**

នៅពេលដែលអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន មន្ត្រីស៊ើបអង្កេតត្រូវៈ

- បញ្ជាក់អំពីឈ្មោះ តួនាទី និងការិយាល័យដែលខ្លួនបម្រើការ
- បង្ហាញដល់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតអំពីគោលបំណងនៃការអនុវត្តនេះ។

បុគ្គលដែលបដិសេធតាមការស្នើសុំ ការទាមទារ ឬការបញ្ជាណាមួយរបស់មន្ត្រីស៊ើបអង្កេត មិនត្រូវចាត់ទុកថាបំពានច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ឬបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀតឡើយ ប្រសិនបើមន្ត្រីស៊ើបអង្កេតមិនអនុវត្តតាមកថាខណ្ឌទី១ នៃប្រការនេះ។

**ប្រការ៧.–**

មន្ត្រីស៊ើបអង្កេតអាចចូលទៅកាន់ទីតាំងណាមួយក្នុងម៉ោងធ្វើធុរកិច្ចធម្មតា ដើម្បីត្រួតពិនិត្យ និងស៊ើបអង្កេតបទល្មើសក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

ក្នុងពេលចូលទៅកាន់ទីតាំងធុរកិច្ច មន្ត្រីស៊ើបអង្កេតអាចៈ

- ត្រួតពិនិត្យ អង្កេតទំនិញ ឬសេវាដោយផ្ទាល់ ព្រមទាំងត្រួតពិនិត្យលើការផ្សាយពាណិជ្ជកម្ម ការលក់ ឬការចែកចាយបន្ត ដើម្បីធានានូវការអនុវត្តស្របតាមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- ឃាត់ និងរក្សាទុកទំនិញ ឬសេវាដែលបានរកឃើញក្នុងទីតាំង ក្នុងករណីដែលមន្ត្រីស៊ើបអង្កេតសង្ស័យថាអាចពាក់ព័ន្ធនឹងការបំពានណាមួយ
- ដកយកសំណាកគំរូមកវិភាគ ដើម្បីកំណត់អំពីការបំពាន
- ថតរូប ឬថតវីដេអូនូវសកម្មភាពនៃការស៊ើបអង្កេត
- អនុវត្តវិធានការដើម្បីរក្សា ឬការពារឯកសារ ទំនិញ ឬសេវា ដែលមន្ត្រីស៊ើបអង្កេតកំណត់ថាមានពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងស៊ើបអង្កេត
- អនុវត្តភារកិច្ចផ្សេងទៀតដែលមន្ត្រីស៊ើបអង្កេតយល់ថាចាំបាច់។

**ប្រការ៨.–**

ប្រសិនបើទំនិញ ឬសេវា ឬឯកសារ ត្រូវបានឃាត់ មន្ត្រីស៊ើបអង្កេតត្រូវរៀបចំបញ្ជីទំនិញ ឬសេវា ឬឯកសារដែលត្រូវបានឃាត់ទុក ហើយត្រូវចុះហត្ថលេខាលើបញ្ជីនោះ ដែលត្រូវធ្វើឡើងចំនួនបីច្បាប់ ដោយមួយច្បាប់ត្រូវផ្តល់ជូនទៅអ្នកទទួលខុសត្រូវទីតាំង ម្ចាស់ ឬអ្នកតំណាង បុគ្គលិក ឬមន្ត្រីទទួលបន្ទុកទីតាំងនោះ និងពីរច្បាប់ទៀតត្រូវរក្សាទុកដោយមន្ត្រីស៊ើបអង្កេត និង គ.ជ.ក.ប.។

ប្រសិនបើទំនិញ ឬសេវានោះត្រូវបានឃាត់ទុកពីម៉ាស៊ីនស្វ័យប្រវត្តិ មន្ត្រីស៊ើបអង្កេតត្រូវៈ

- ផ្ញើបញ្ជីទំនិញ ឬសេវា ដែលត្រូវបានឃាត់ទុកនោះទៅបុគ្គលជាម្ចាស់ទំនិញ ឬសេវាតាមរយៈឈ្មោះ ឬអាសយដ្ឋានដែលមាននៅលើម៉ាស៊ីនស្វ័យប្រវត្តិនោះ។
- ផ្តល់បញ្ជីទំនិញ ឬសេវា ដែលត្រូវបានឃាត់ទុកនោះទៅម្ចាស់ទីតាំងដែលម៉ាស៊ីនស្វ័យប្រវត្តិនោះស្ថិតនៅ ប្រសិនបើគ្មានឈ្មោះ ឬអាសយដ្ឋានទេ។
- បិទបញ្ជីទំនិញ ឬសេវា ដែលត្រូវបានឃាត់ទុកនោះ នៅទីតាំងម៉ាស៊ីនស្វ័យប្រវត្តិនោះតែម្តង ប្រសិនបើមិនមានឈ្មោះ និងអាសយដ្ឋាននៅលើម៉ាស៊ីនស្វ័យប្រវត្តិ និងមិនមានវត្តមានម្ចាស់ទីតាំងដែលម៉ាស៊ីនស្វ័យប្រវត្តិស្ថិតនៅទេនោះ។

**ប្រការ៩.–**

ការយកសំណាកគំរូ ត្រូវអនុវត្តតាមនីតិវិធីនៃការយកសំណាកគំរូ (Sampling SOP) ។

**ប្រការ១០ ._**

១. មន្ត្រីស៊ើបអង្កេតអាចចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជូនទៅ បុគ្គលស្ថិតក្រោមការស៊ើបអង្កេត ឬបុគ្គលពាក់ព័ន្ធ ដោយតម្រូវឱ្យបុគ្គលនោះផ្តល់ឯកសារពាក់ព័ន្ធ ឬព័ត៌មានជាក់លាក់ណាមួយប្រសិនបើមន្ត្រីស៊ើបអង្កេតយល់ថាព័ត៌មានទាំងនោះមានពាក់ព័ន្ធនឹងដំណើរការត្រួតពិនិត្យ និងស៊ើបអង្កេត។ សេចក្តីជូនដំណឹងត្រូវ៖

- បង្ហាញគោលបំណងនៃការស្វែងរកព័ត៌មាន ឯកសារ ឬវត្ថុជាក់លាក់ណាមួយ ដែលមន្ត្រីស៊ើបអង្កេតយល់ថាពាក់ព័ន្ធនឹងការបំពាន
- បញ្ជាក់អំពីពេលវេលា ទីកន្លែង វិធី និងទម្រង់នៃការរៀបចំព័ត៌មាន ឯកសារ ឬវត្ថុជាក់លាក់ណាមួយ។

២. មន្ត្រីស៊ើបអង្កេតអាចតម្រូវឱ្យបុគ្គលស្ថិតក្រោមការស៊ើបអង្កេត ឬបុគ្គលពាក់ព័ន្ធថតចម្លងទាំងស្រុង ឬផ្នែកណាមួយ និងផ្តល់ការបកស្រាយចំពោះព័ត៌មាន ឯកសារ ឬវត្ថុនោះ។

៣. ប្រសិនបើព័ត៌មាន ឯកសារ ឬវត្ថុណាមួយ ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការនេះមិនត្រូវបានផ្តល់ជូនមន្ត្រីស៊ើបអង្កេតតាមការតម្រូវទេ បុគ្គលដែលមិនបានផ្តល់នោះត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរ ក្នុងទម្រង់មួយដែលបង្ហាញពីហេតុផលសមស្របនៃការមិនបានបំពេញតាមការតម្រូវ។

៤. ប្រសិនព័ត៌មានត្រូវបានផ្តល់ដោយផ្ទាល់មាត់ មន្ត្រីស៊ើបអង្កេតត្រូវធ្វើកំណត់ហេតុ និងអានកំណត់ហេតុ ជូនដល់បុគ្គលដែលបានផ្តល់ព័ត៌មាន បន្ទាប់មកបុគ្គលផ្តល់ព័ត៌មានត្រូវចុះហត្ថលេខាលើកំណត់ហេតុនោះ។ ប្រសិនបើបុគ្គលផ្តល់ព័ត៌មានបដិសេធចុះហត្ថលេខាលើកំណត់ហេតុ មន្ត្រីស៊ើបអង្កេតត្រូវកត់ត្រាជាលាយលក្ខណ៍អក្សរអំពីការបដិសេធនោះ ហើយត្រូវនិទ្ទេស កាលបរិច្ឆេទ និងចុះហត្ថលេខាសង្ខេបលើគ្រប់ទំព័រនៃកំណត់ហេតុនោះ។

**ប្រការ១១ ._**

ក្នុងការអនុវត្តសិទ្ធិ និងកាតព្វកិច្ច ដូចបានកំណត់ក្នុងមាត្រា៣០ នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ មន្ត្រីស៊ើបអង្កេតត្រូវទុកដាក់ និងគ្រប់គ្រងទំនិញ ឯកសារ ឬវត្ថុដទៃទៀត ដែលត្រូវបានឃាត់ទុកតាមរយៈសេចក្តីជូនដំណឹងឱ្យមានសុវត្ថិភាពហូតបញ្ចប់នីតិវិធីត្រួតពិនិត្យ និងស៊ើបអង្កេត។

ប្រសិនបើតម្រូវឱ្យមានការវិភាគ ឬការធ្វើតេស្ត ដែលជាផ្នែកមួយនៃការស៊ើបអង្កេត ដើម្បីកំណត់អំពីអនុលោមភាពទៅនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ មន្ត្រីស៊ើបអង្កេតត្រូវខិតខំក្នុងហេតុផលសមស្របណាមួយ ដើម្បីធ្វើឱ្យការប៉ះពាល់ដល់ទំនិញ ឯកសារ ឬវត្ថុទាំងនោះមានទំហំមួយយ៉ាងតិចបំផុត។

**ប្រការ១២ ._**

១. មន្ត្រីស៊ើបអង្កេត អាចចេញសេចក្តីជូនដំណឹងស្តីពីវិធានការហាមឃាត់ជាបណ្តោះអាសន្នក្នុងការលក់ ការផ្គត់ផ្គង់ ឬការចែកចាយ ឬចរាចរណ៍លើទីផ្សារ នូវទំនិញ ឬសេវា រួមទាំងមធ្យោបាយដឹកជញ្ជូន និងឧបករណ៍សម្រាប់បម្រើការក្លែងបន្លំ ដោយត្រូវចុះហត្ថលេខាលើសេចក្តីជូនដំណឹងនោះ ក្នុងករណីដែលមន្ត្រីស៊ើបអង្កេតយល់ឃើញថាទំនិញ ឬសេវានោះ៖

ក. មិនអនុលោមតាមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់

ខ. បង្ក ឬអាចបង្កឱ្យមានគ្រោះថ្នាក់ដល់បុគ្គលណាមួយ

គ. អាចបង្កឱ្យគ្រោះថ្នាក់ដល់បុគ្គលណាមួយ ប្រសិនបើការប្រើប្រាស់ទំនិញ ឬសេវាមិនសមស្រប ឬប្រើប្រាស់ខុសនីតិវិធី។

២. សេចក្តីជូនដំណឹងស្តីពីវិធានការហាមឃាត់ជាបណ្តោះអាសន្នខាងលើ ត្រូវ៖

ក. បញ្ជាក់ឈ្មោះរបស់មន្ត្រីស៊ើបអង្កេត ដែលទទួលបន្ទុកអនុវត្តការត្រួតពិនិត្យ និងស៊ើបអង្កេត

ខ. បញ្ជាក់អំពីប្រភេទទំនិញ ឬសេវា ដែលជាកម្មវត្ថុនៃសេចក្តីជូនដំណឹងនោះ

គ. បញ្ជាក់អំពីភាពមិនអនុលោមរបស់ទំនិញ ឬសេវា ឬសកម្មភាពបំពានផ្សេងទៀតក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់

ឃ. បញ្ជាក់អំពីកាលបរិច្ឆេទ អាជ្ញាយុកាល និងសិទ្ធិរបស់ភាគីទាំងអស់ដែលជាកម្មវត្ថុនៃសេចក្តីជូនដំណឹង

ង. បញ្ជាក់អំពីទោសទណ្ឌ និងការពិន័យ ក្នុងករណីដែលមិនអនុវត្តតាមសេចក្តីជូនដំណឹង។

៣. សេចក្តីជូនដំណឹងស្តីពីវិធានការហាមឃាត់ជាបណ្តោះអាសន្នត្រូវអនុវត្តភ្លាម បន្ទាប់ពីសេចក្តីជូនដំណឹងនេះត្រូវបានផ្តល់ជូនទៅបុគ្គលពាក់ព័ន្ធ ឬតំណាង ឬបុគ្គលិករបស់បុគ្គលនោះ។

៤. សេចក្តីជូនដំណឹងស្តីពីវិធានការហាមឃាត់ជាបណ្តោះអាសន្ន ត្រូវមានសុពលភាពមិនលើសពី ៣០ (សាមសិប) ថ្ងៃ ហើយអាចបន្តសុពលភាពបានម្តងទៀត។

៥. ក្នុងករណីមិនសុខចិត្តនឹងវិធានការហាមឃាត់ជាបណ្តោះអាសន្នរបស់មន្ត្រីស៊ើបអង្កេត បុគ្គលពាក់ព័ន្ធមានសិទ្ធិប្តឹងតវ៉ាទៅ គ.ជ.ក.ប. ក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបានសេចក្តីជូនដំណឹងស្តីពីវិធានការហាមឃាត់ជាបណ្តោះអាសន្ន។ គ.ជ.ក.ប. ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងការពិនិត្យឡើងវិញ កែប្រែ ឬមោឃភាព លើវិធានការហាមឃាត់ជាបណ្តោះអាសន្ន ក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ គិតចាប់ពីថ្ងៃបានទទួលពាក្យបណ្តឹងតវ៉ានោះ។

៦. ក្នុងករណីមិនសុខចិត្តនឹងការសម្រេចរបស់អគ្គនាយកនៃអគ្គនាយកដ្ឋាន ក.ប.ប. បុគ្គលពាក់ព័ន្ធមានសិទ្ធិប្តឹងទៅ គ.ជ.ក.ប. ក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបានការសម្រេចរបស់អគ្គនាយកនៃអគ្គនាយកដ្ឋាន ក.ប.ប. ហើយ គ.ជ.ក.ប. ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងការពិនិត្យឡើងវិញ កែប្រែ ឬមោឃភាព លើការសម្រេចរបស់អគ្គនាយកនៃអគ្គនាយកដ្ឋាន ក.ប.ប. ក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ គិតចាប់ពីថ្ងៃបានទទួលពាក្យបណ្តឹងតវ៉ានោះ។

៧. ការប្តឹងតវ៉ាខាងលើត្រូវផ្តល់ភស្តុតាងដែលបញ្ជាក់ថា ទំនិញ ឬសេវានោះ អនុលោមតាមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់។

**ប្រការ១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៤ .-**

សមាសភាពគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៨រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**និងជាប្រធានគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់**

**ប៉ាន_សូរស័ក្តិ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ